**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស**
**លេខ:** ០០៥/១៧ [illegible]

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

នៅថ្ងៃសុក្រទី២៥ ខែសីហា ឆ្នាំ២០១៧ វេលាម៉ោង៨ និង ៣០នាទីព្រឹក នៅវិមានសន្តិភាព មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លងៈ

**១- សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦។**
**២- សេចក្តីព្រាងគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ ។**
**៣- សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១៨-២០២០។**
**៤- បញ្ហាផ្សេងៗ ។**

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័តៈ

**១- សេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០០៦។**

ស្របតាមស្ថានភាពរីកចម្រើននៃសង្គមជាតិ ជាពិសេសលើវិស័យជលផល នៅឆ្នាំ២០០៦ ច្បាប់ស្តីពីជលផលថ្មីមួយ ត្រូវបានរៀបចំកែសម្រួល និងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលរួមមាន១៧ ជំពូក និង១០៩ មាត្រា។

នៅឆ្នាំ២០១១ ក្នុងឱកាសទិវាមច្ឆជាតិនៅខេត្តស្វាយរៀង សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានណែនាំ និងផ្តល់អនុសាសន៍ឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានរដ្ឋបាលជលផលទទួលបន្ទុកផ្ទាល់ ធ្វើការសិក្សាស្រាវជ្រាវដើម្បីរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីជលផលនេះឡើងវិញ ដោយធ្វើការកែសម្រួលអំពីការគ្រប់គ្រងធនធានជលផលផ្អែកតាមតម្រូវការ និងស្ថានភាពរីកចម្រើននៃសង្គមជាតិ។

ខ្លឹមសារសំខាន់ៗនៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផលរៀបចំឡើងរួមមានៈ

ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៤១ មហាវិថីសហព័ន្ធរុស្ស៊ី
ទូរសារលេខ: ០២៣ ២១២ ៤៩០, ទូរស័ព្ទ: [illegible] ០៩៧ ៧ ៩៧០ ៦០៩
អ៊ីមែល: pressocm@gmail.com

១-កែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលជលផល ដែលចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅថ្នាក់ជាតិ ត្រូវដាក់ឱ្យស្ថិតនៅចំណុះមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត នៅថ្នាក់ក្រោមជាតិ។

២-កែសម្រួលបន្ថយទំហំក្រឡាសាច់មង ឬអួន តាមសំណើ និងសំណូមពររបស់ប្រជានេសាទ។

៣-ផ្ដល់សិទ្ធិធ្វើនេសាទដោយឧបករណ៍នេសាទលបណ ឬរ៉ាវ ឬលបឡុក និងឧបករណ៍អួន ជូនប្រជានេសាទតាមសំណូមពរ និងតម្រូវការជាក់ស្ដែង។

## ២- សេចក្ដីព្រាងគោលនយោបាយជាតិស្ដីពីមនុស្សវ័យចាស់ ២០១៧-២០៣០ ។

អនុលោមយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៣ ការធ្វើបច្ចុប្បន្នភាពគោលនយោបាយមនុស្សចាស់ឆ្នាំ២០០៣ គឺជាភារកិច្ចរបស់យើងទាំងអស់គ្នាក្នុងការអនុវត្តសកម្មភាពនយោបាយអាទិភាពដែលផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ២០១៤-២០១៨ បានកំណត់។ ដូចគ្នានេះដែរ គោលនយោបាយជាតិប្រជាជន២០១៦-២០៣០ ក៏បានចង្អុលបង្ហាញឱ្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងស្ថាប័នពាក់ព័ន្ធ ដែលមានតួនាទីដោះស្រាយបញ្ហាពាក់ព័ន្ធ នឹបញ្ហាសុខភាព ស្ថានភាពសេដ្ឋកិច្ច សកម្មភាពចូលរួមក្នុងសង្គម និងសុខុមាលភាពទូទៅ ត្រូវសហការរៀបចំគោលការណ៍ណែនាំ និងគោលនយោបាយជាតិស្ដីពីមនុស្សវ័យចាស់ ដើម្បីឆ្លើយតបនឹងសេចក្ដីត្រូវការរបស់មនុស្សចាស់ ដែលមានចំនួនកាន់តែកើនឡើង។

ការតម្រង់ទិសជាលក្ខណៈគោលនយោបាយនេះ មានហេតុផលមួយទៀតសម្រាប់ធ្វើបច្ចុប្បន្នភាពគោលនយោបាយមនុស្សចាស់ឆ្នាំ២០០៣ គឺដើម្បីដោះស្រាយបញ្ហាមនុស្សចាស់ដែលមានការកើនឡើង ដោយផ្អែកលើបរិការណ៍ អភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចនិងស្ថានភាពប្រជាសាស្ត្រ និងផលប៉ះពាល់ចំពោះការអភិវឌ្ឍ ក៏ដូចជាលើគោលការណ៍ណែនាំរបស់ផែនការសកម្មភាពអន្តរជាតិទីក្រុងម៉ាឌ្រីត ស្ដីពីមនុស្សចាស់ និងសេចក្ដីសម្រេចរបស់សន្និបាតពិភពលោកលើកទី២ ស្ដីពីមនុស្សចាស់នៅឆ្នាំ២០០២។ សេចក្ដីព្រាងគោលនយោបាយនេះ ផ្ដោតលើមធ្យោបាយ និងលទ្ធភាពទាំងឡាយដើម្បីដោះស្រាយបញ្ហារបស់មនុស្សវ័យចាស់ ដែលលេចចេញពីបម្រែបម្រួលប្រជាសាស្ត្រ។ ការឈានចូលវ័យចាស់របស់ប្រជាជនកម្ពុជាកំពុងកើនឡើងក្នុងអត្រាខ្ពស់ជាងមុន ហើយនិន្នាការនៃការកើនឡើងនេះត្រូវបានព្យាករណ៍ថា នឹងបន្តកើនឡើងទៀត។ ការកើនឡើងនៃចំនួនមនុស្សវ័យចាស់នេះ ដោយសារកត្តា២ គឺការថយចុះនៃលទ្ធភាពមានកូន និងភាពប្រសើរឡើងនៃអាយុកាលសង្ឃឹមរស់។ ភាគរយប្រជាជនកម្ពុជា អាយុ៦០ឆ្នាំឡើងមានចំនួន៨% នៅឆ្នាំ២០១៣ នឹងមាននិន្នាការកើនឡើងដល់ ១១% នៅឆ្នាំ២០៣០។

ចាប់ពីឆ្នាំ២០០៣មក វឌ្ឍនភាពនៃវិស័យសង្គមកិច្ច និងវិស័យសេដ្ឋកិច្ច បានរីកចម្រើនយ៉ាងឆាប់រហ័ស។ វឌ្ឍនភាពនេះ ពាក់ព័ន្ធនឹងការធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃជីវិតរបស់ប្រជាជន ជាពិសេស អាយុកាលសង្ឃឹមរស់ កើនឡើងពី៥៨ឆ្នាំសម្រាប់បុរស និង៦៤ឆ្នាំសម្រាប់ស្ត្រី នៅឆ្នាំ២០០៤ ដល់៦៧ឆ្នាំ សម្រាប់បុរស់ និង៧១ឆ្នាំសម្រាប់ស្ត្រី នៅឆ្នាំ២០១៣ ស្ថានភាពអត្រាមរណភាពរបស់មាតាបានថយចុះពី៤៦១នាក់ក្នុង១០០ ០០០ កំណើតរស់នៅក្នុងឆ្នាំ២០០៤ មក១៧០នាក់នៅឆ្នាំ២០១៤ និងអត្រាមរណភាពរបស់កុមារអាយុក្រោម៥ឆ្នាំ បានថយចុះយ៉ាងខ្លាំងពី ១២៤នាក់ក្នុងចំណោមកុមារ១០០០នាក់ នៅឆ្នាំ២០០០ មកត្រឹម៣៥នាក់នៅឆ្នាំ២០១៤ និង

ស្ថានភាពសុខភាពបន្តពូជ។ ការទទួលបានការអប់រំកាន់តែប្រសើរ បានកាត់បន្ថយទាំងគម្លាតរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ ទាំងយុគភាពយេនឌ័រ ក្នុងវិស័យអប់រំ។ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាច្រើន ត្រូវបានបង្កើតឡើង ជំរុញឱ្យមានកំណើនសេដ្ឋកិច្ចក្នុងប្រជាជនម្នាក់ កើនឡើងពី ៣៦៧ ដុល្លារក្នុងឆ្នាំ២០០៣ ដល់១៣០០ដុល្លារក្នុងឆ្នាំ២០១៦ ការបង្កើតការងារថ្មី និងអត្រានៃភាពក្រីក្ររបស់ប្រជាជន ត្រូវបានកាត់បន្ថយពី២២,៩% ក្នុងឆ្នាំ២០០៩ មកនៅជុំវិញ១៤% ក្នុងឆ្នាំ២០១៤។

គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់២០១៧-២០៣០ បានពិនិត្យមើលអំពីស្ថានភាពបច្ចុប្បន្ននៃការអភិវឌ្ឍសង្គមកិច្ច សេដ្ឋកិច្ច និងប្រជាសាស្ត្រ វិភាគអំពីផលវិបាកចម្បងៗ និងមនុស្សចាស់ មកលើការអភិវឌ្ឍក្នុងពេលបច្ចុប្បន្ន និងអនាគតហើយក៏បានកំណត់កត្តាជាអាទិភាពចំនួន៩ ទាក់ទងទៅនឹងមនុស្សវ័យចាស់ រួមមាន៖ (១)សន្តិសុខហិរញ្ញវត្ថុ, (២)សុខភាព និងសុខុមាលភាព, (៣)របៀបរបបការរស់នៅ, (៤)បរិស្ថានអំណោយផល, (៥)វ័យចាស់សកម្ម និងសមាគមមនុស្សចាស់, (៦)ទំនាក់ទំនងអន្តរជំនាន់, (៧)ការរំលោភបំពាន ការមិនអើពើ និងអំពើហិង្សាលើមនុស្សចាស់ (៨)ស្ថានភាពមានអាសន្ន, និង(៩)ការត្រៀមខ្លួនរបស់មនុស្សវ័យក្មេងសម្រាប់ការឈានចូលវ័យចាស់។

យោងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងសេចក្តីប្រកាសទីក្រុងក្វាឡាឡាំពួ ស្តីពីមនុស្សចាស់ឆ្នាំ២០១៥ គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ កំណត់យកអាយុ៦០ឆ្នាំជាមនុស្សចាស់។

## ៣- សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១៨-២០២០ ។

កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១៨-២០២០ ត្រូវបានរៀបចំឡើងដោយគិតគូរដល់កត្តាចម្បង និងស្ថានភាពជាក់ស្តែងបីសំខាន់គឺ៖ ទី១ ការបង្ហាញពីទិន្នន័យនៃគម្រោងវិនិយោគ ដែលជាគោលនយោបាយមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ និងជាផែនទីចង្អុលផ្លូវ សម្រាប់ការអនុវត្តគោលនយោបាយដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ទី២ តម្រូវការចំណាយសរុបសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ និងទី៣ បរិមាណហិរញ្ញប្បទានសហប្រតិបត្តិការ។

ការវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នៅឆ្នាំ២០១៦ បានបង្ហាញពីវឌ្ឍភាព និងបញ្ហាប្រឈម ដែលប៉ះពាល់ដល់ដំណើរការអភិវឌ្ឍន៍ដែលទាមទារឱ្យមានការប្រឹងប្រែងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ថែមទៀត ដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់៧%ក្នុងមួយឆ្នាំ និងទិសដៅអាទិភាពនានាសំដៅគាំទ្រប្រជាជនក្រីក្រ ដូចជាការអភិវឌ្ឍកសិកម្ម តាមរយៈការលើកកម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម។ ការងារទាំងនេះគឺជាអាទិភាព ដែលអាចផ្តល់ផលប្រយោជន៍ចំពោះមុខនិងយូរអង្វែង ក៏ដូចជាផ្តល់នូវបណ្តាញសុវត្ថិភាពសង្គម សម្រាប់ប្រជាជនក្រីក្រ ព្រមទាំងអាចបង្កើនអំណាចទិញ និងសុខុមាលភាពរបស់ពួកគាត់ ធានានូវចីរភាពកំណើនសេដ្ឋកិច្ច និងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ចឱ្យបានទូលាយជាងមុន។ កិច្ចខិតខំប្រឹងប្រែងអនុវត្តឱ្យបានសម្រេចនូវគោលដៅទាំងនេះ គឺជាអាទិភាពចម្បងនៅក្នុងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០១៨-២០២០ ដែលធនធានប្រមាណ៦០% ត្រូវបានបន្តវិភាជន៍សម្រាប់ការវិនិយោគនៅតំបន់ជនបទ។

ក្នុងចំនួនគម្រោងសរុប៥៨៦ គម្រោងនៃកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលនេះ មានចំនួន១៦៦គម្រោង គឺជាគម្រោងកំពុងដំណើរការដែលត្រូវការទុនចំនួន[illegible]លានដុល្លារ

អាមេរិក និងចំនួន៤២០គម្រោងទៀត គឺជាគម្រោងសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ដែលត្រូវការទុនចំនួន២៨៨១លានដុល្លារអាមេរិក។ ជាសរុបបរិមាណទុនតាមឆ្នាំរបស់កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០១៨-២០២០ រួមមានឆ្នាំ២០១៨ ចំនួន១៩១៨លានដុល្លារអាមេរិក ឆ្នាំ២០១៩ ចំនួន១៧៨៥លានដុល្លារអាមេរិក និងឆ្នាំ២០២០ ចំនួន១៧១៤លានដុល្លារអាមេរិក។ បរិមាណទុនសរុប៥៤១៧លានដុល្លារអាមេរិកនៃកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល ២០១៨-២០២០រួមបញ្ចូលនូវបរិមាណទុនដែលបានសន្យាផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍរួចហើយមានចំនួន៣៤៥៥,១លានដុល្លារអាមេរិក ក្នុងនោះពីរាជរដ្ឋាភិបាលចំនួន៥៣៧លានដុល្លារអាមេរិក និងពីដៃគូអភិវឌ្ឍចំនួន២៩១៨,១លានដុល្លារអាមេរិក ដោយត្រូវការទុនបន្ថែម ចំនួន១៩៦១,៨ លានដុល្លារអាមេរិក។ ការវិភាជទុនដល់គម្រោងនានារបស់កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល២០១៨-២០២០ ទៅតាមវិស័យដូចបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨រួមមាន៖

- ១៥,៣% នៃតម្រូវការចំណាយវិនិយោគសាធារណៈសរុបសម្រាប់អនុវត្តគម្រោងក្នុងវិស័យសង្គមកិច្ច
- ៤៤% នៃតម្រូវការចំណាយវិនិយោគសាធារណៈសរុបសម្រាប់អនុវត្តគម្រោងក្នុងវិស័យសេដ្ឋកិច្ច
- ២៦,៩% នៃតម្រូវការចំណាយវិនិយោគសាធារណៈសរុបសម្រាប់អនុវត្តគម្រោងក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ
- ១៣,៨%នៃតម្រូវការចំណាយវិនិយោគសាធារណៈសរុបសម្រាប់អនុវត្តគម្រោងក្នុងវិស័យសេវា និងកម្មវិធីអន្តរវិស័យ។

**៣- បញ្ហាផ្សេងៗ៖**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើការណែនាំ៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវត្រៀមរៀបចំ អាវភ្លៀង អាវងារ សម្រាប់ចែកជូនកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទដែលឈរជើងនៅតាមខ្សែបន្ទាត់ព្រំដែនអោយបានទាន់ពេលវេលា។
- ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងស្ថាប័នពាក់ព័ន្ធត្រូវរៀបចំ ឱ្យបានឆាប់រហ័សនូវប្រព័ន្ធប្រាក់សោធននិវត្តន៍ សម្រាប់កម្មករ កម្មការិនី ឱ្យបានទូលំទូលាយដែលអាចគ្របដណ្តប់លើវិស័យដទៃទៀត និងបន្តជំរុញការតបណ្តាញទឹក ភ្លើងតាមខ្នងផ្ទះជួលដែលកម្មករស្នាក់នៅ។
- អាជ្ញាធររាជធានី ខេត្ត ត្រូវសហការពិភាក្សាជាមួយម្ចាស់ផ្ទះ ឬបន្ទប់ជួល ដើម្បីកុំឱ្យតម្លើងថ្លៃឈ្នួលយ៉ាងតិចរយៈពេល២ឆ្នាំនេះ ក្នុងពេលដែលប្រាក់ឈ្នួលកម្មករត្រូវបានតំឡើង។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១០ និង៣៥នាទី។

រាជធានីភ្នំពេញ, ថ្ងៃសុក្រ ទី ២៥ ខែ សីហា ឆ្នាំ ២០១៧